ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមគោរពជូន
សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអុន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៦

សម្តេចកិត្តិសង្គហបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងវិកាសដ៏សោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៦ ខាងមុខនេះ: តាងនামថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមគោរពជូនពរបវរមហាប្រសើរវិជ្ជាជីវៈជូន **សម្តេចកិត្តិសង្គហបណ្ឌិត** សូម១ ទទួលបាននូវសុខភាពល្អបរិបូរ: កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណកងវៃ ជន្មាយុយืนយូរ: ដើម្បីបន្ត្រមចំណែកកសាង និងអភិវឌ្ឍមាតុភូមិកម្ពុជា ឱ្យសម្រេចបាននូវសមិទ្ធផលធំត្រចះត្រចង់ថ្មីៗថែមទៀត។

ម្យ៉ាងក្នុងវិកាសនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរពកោតសរសើរយ៉ាងក្រៃលែងនូវការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចកិត្តិសង្គហបណ្ឌិត** ដែលកន្លងមកតែងបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញា ស្មារតី ជាមួយនឹងបទពិសោធដ៏ប៉ិនប្រសប់ក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ ព្រមទាំងការលះបង់ត្រាប់ បែបយ៉ាងដើម្បីបម្រើឧត្តមប្រយោជន៍ ជាតិ សាសនា ព្រះមហាក្សត្រ និងការការពារសុខសន្តិភាពឯករាជ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមគ្នានេះ: ការលះបង់ដ៏ធំធេងរបស់ **សម្តេច** ក្នុងការរួមចំណែកស្តារ: និងកសាងប្រទេស គឺជាសំវ:ភាពដ៏មានតម្លៃសម្រាប់អ្នកបន្តវេនជំនាន់ក្រោយក្នុងការសិក្សារៀនសូត្រ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។

ជាប្តីម្តងទៀត ក្នុងនামថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងផល់ព្រះសិរីសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរជ័យ សិរីមង្គល ជូនចំពោះ: **សម្តេចកិត្តិសង្គហបណ្ឌិត** ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ: វណ្ណ: សុខ: ពល: កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអុន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ១៤ ១៥ ១៦ ១៧ ១៨ ១៩ ២០ ២១ ២២ ២៣ ២៤ ២៥ ២៦ ២៧ ២៨ ២៩ ២០ ១ ២ ១ ២ ១ ២